ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ១៦៩៥ អ.ក

ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩

**សាលក្រម**

លេខ ០៤២ "ក"

ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ០៩: ០០ នាទីព្រឹក ដោយមានសមាសភាព ៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៥ អ.ក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] ជួន ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] កន "រស់" មានកូន ០៨នាក់ ឪពុកឈ្មោះ [redacted] ចែម "ស្លាប់" ម្តាយឈ្មោះ [redacted] សឿប "ស្លាប់" ទោសពីមុន -គ្មាន- ជានីតិជន (ក្រៅឃុំ) ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ៖ ហិង្សាស្រាល ប្រព្រឹត្តនៅចំណុចព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល ភេទស្រី អាយុ៥៨ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។



Scanned with CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៦ និង ០០នាទី ស្ថិតនៅភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជនសង្ស័យឈ្មោះ [redacted] ជួន បានទៅផ្ទះលោកមេភូមិ ដើម្បីធ្វើលិខិតបញ្ជាក់ដីធ្លីរបស់ខ្លួន ។ ប៉ុន្តែលោកមេភូមិបានប្រាប់ថា ដីនោះត្រូវបានឈ្មោះ [redacted] សុផល ត្រូវជាប្អូនរបស់ឈ្មោះ [redacted] ជួន ជំទាស់។ ពេលនោះជនសង្ស័យឈ្មោះ [redacted] ជួន បានខឹងនិងឈ្មោះ [redacted] សុផល យ៉ាងខ្លាំង ហើយក៏សំដៅទៅផ្ទះរបស់ឈ្មោះ [redacted] សុផល ដែលកំពុងអង្គុយលើគ្រែ រួចក៏មានទំនាស់ពាក្យសម្ដីនឹងគ្នា បន្ទាប់មកជនសង្ស័យឈ្មោះ [redacted] ជួន បានចាប់ទាញឈ្មោះ [redacted] សុផល ទម្លាក់ពីលើគ្រែធ្លាក់អុកគូទទៅលើដី។

-**បានឃើញ** របាយការណ៍លេខ ៤៩៦ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ០៤៤ ដកជរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ជួន បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយក៏មិនបានវាយគេទេ ។ ខ្លួននិងឈ្មោះ [redacted] សុផល ត្រូវជាបងប្អូននឹងគ្នា ។ នៅថ្ងៃកើតហេតុ ខ្លួនមានទំនាស់ជាមួយឈ្មោះ [redacted] សុផល ទាក់ទងនឹងរឿងដីរបស់ខ្លួន ដោយខ្លួនបានទៅហៅ និងទាញដៃឈ្មោះ [redacted] សុផល ដើម្បីទៅផ្ទះមេភូមិទាំងអស់គ្នា ប៉ុន្តែខ្លួនមិនបានទាញឈ្មោះ [redacted] សុផល ទម្លាក់ពីលើគ្រែទេ ។ បច្ចុប្បន្នខ្លួនឈប់ឈ្លោះគ្នាជាមួយឈ្មោះ [redacted] សុផល ទៀតហើយ ។ សំណូមពរ សុំឲ្យតុលាការបញ្ចប់រឿងត្រឹមនេះ ។

-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល បានឆ្លើយថា៖ ដោយថ្ងៃកើតហេតុឈ្មោះ [redacted] ជួន បានដើរមកផ្ទះខ្លួន ពេលនោះខ្លួនកំពុងតែអង្គុយលើគ្រែសណ្ដូកជើងមកមុខ ហើយខ្លួនក៏បានសួរទៅឈ្មោះ [redacted] ជួន ថា លោកបងទៅណា ស្រាប់តែឈ្មោះ [redacted] ជួន បានចាប់ទាញជើងខ្លួនទាំងពីរទម្លាក់ពីលើគ្រែដែលមានកំពស់មួយម៉ែត្រជាង នៅពេលនោះមានក្មួយរបស់ខ្លួនបានមកទ្រខ្លួន ហើយឈ្មោះ [redacted] ជួន បានយាដៃវៃខ្លួន ក៏ត្រូវក្មួយបានប្រលែងខ្លួន ហើយទៅចាប់ដៃឈ្មោះ [redacted] ជួន ធ្វើឲ្យធ្លាក់អុកគូទមកលើដីបណ្ដាលឲ្យឈឺ និងជាំ ។ នៅពេលដែលឈ្មោះ [redacted] ជួន ទាញខ្លួនទម្លាក់ពីលើគ្រែ នៅពេលនោះខ្លួនកំពុងតែមានជំងឺ ក្រោយពីវះកាត់ចំនួនពីរលើកមកហើយ ។ ហើយក្រោយកើតហេតុខ្លួនក៏បានទៅព្យាបាលនៅមន្ទីរពេទ្យឯកជន ។ ហើយឈ្មោះ [redacted] ជួន និងខ្លួនធ្លាប់មានទំនាស់គ្នាពីរឿងដីធ្លី តែពុំដែលបានជួបមុខគ្នាទេ ហើយឈ្មោះ [redacted] ជួន និងខ្លួន ត្រូវជាបងប្អូន ។



Scanned with CamScanner

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សាម៉ុន បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបាននៅអង្គុយនិយាយ លេងជាមួយឈ្មោះ [redacted] សុផល នៅក្រោមផ្ទះរបស់ឈ្មោះ [redacted] សុផល ដោយគាត់អង្គុយសណ្តូកជើងលើគ្រែ ហើយខ្លួនអង្គុយកៅអី ស្រាប់តែឃើញឈ្មោះ [redacted] ផួន មកសួរនាំរឿងដីធ្លី ហើយបានទាញជើងឈ្មោះ [redacted] សុផល ទម្លាក់ពីលើគ្រែកំពស់ជាងមួយម៉ែត្រ ប៉ុន្តែត្រូវបានខ្លួនចាប់ស្មាគាត់ជាប់ ហើយឈ្មោះ [redacted] ផួន បានយកដៃបំរុងវាយឈ្មោះ [redacted] សុផល ទៀត ខ្លួនក៏បានស្ទុះទៅឃាត់ ដោយលែងឈ្មោះ [redacted] សុផល ទើបបណ្តាលឱ្យអុកគូទទៅដី ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សុខខេង បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបាននៅអង្គុយលក់ទំនិញនៅផ្ទះ ទល់មុខផ្ទះម្តាយខ្លួនឈ្មោះ [redacted] សុផល ស្រាប់តែឃើញអ៊ុំខ្លួនឈ្មោះ [redacted] ផួន មកសួររកឪពុកខ្លួន តែខ្លួនថា គាត់មិននៅទេ នៅតែម្តាយនៅក្នុងផ្ទះ ។ ឈ្មោះ [redacted] ផួន បានដើរចូលទៅក្នុងផ្ទះម្តាយខ្លួន មួយសន្ទុះក្រោយមក ស្រាប់តែឮសម្លេងរ៉ូសរ៉ាស ខ្លួនក៏ទៅមើលឃើញឈ្មោះ [redacted] សាម៉ុន និងឈ្មោះ [redacted] ចាន់ធា បាននាំគ្នាឃាត់ចាប់ទាញឈ្មោះ [redacted] ផួន ថយចេញ និងឃើញម្តាយខ្លួនដើរទ្រិបទ្រាបៗ មកអង្គុយនៅកាំជណ្តើរផ្ទះ ហើយឈ្មោះ [redacted] សាម៉ុន បានប្រាប់ខ្លួនថា ឈ្មោះ [redacted] ផួន បានទាញជើងម្តាយខ្លួនទម្លាក់ពីលើគ្រែ តែបានគាត់ជួយទាន់ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ចាន់ធា បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួន និងឪពុកខ្លួនឈ្មោះ [redacted] ផួន បាននាំគ្នាទៅផ្ទះមេភូមិ ដើម្បីធ្វើលិខិតបញ្ជាក់ដីធ្លី តែត្រូវមេភូមិប្រាប់ថា ដីនោះឈ្មោះ [redacted] សុផល បានជំទាស់ ឮដូច្នោះឪពុកខ្លួនខឹង និងបានដើរសំដៅផ្ទះឈ្មោះ [redacted] សុផល ហើយបានចាប់ស្មាទាំងសងខាងរបស់ឈ្មោះ [redacted] សុផល និងទាញឱ្យចុះពីលើគ្រែ ដើម្បីទៅផ្ទះមេភូមិ ។ តែឈ្មោះ [redacted] សុផល មិនព្រម ហើយឈ្មោះ [redacted] សាម៉ុន ក៏បានចាប់ទាញស្មាម្ខាងរបស់ឈ្មោះ [redacted] សុផល ទប់កុំឱ្យធ្លាក់ពីលើគ្រែ តែឈ្មោះ [redacted] សុផល ក៏បានរអិលពីលើគ្រែមកឈរលើដី តែគាត់មិនបានធ្លាក់ពីលើគ្រែទេ ចំណែកខ្លួនក៏បានស្ទុះទៅចាប់ឪពុកខ្លួនចេញ ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ជនជាប់ចោទបានឆ្លើយថា នៅថ្ងៃកើតហេតុ គឺជនជាប់ចោទពិតជាមានទំនាស់ជាមួយជនរងគ្រោះមែន ហើយបានទាញជើងជនរងគ្រោះ តែមិនធ្លាក់ ។ ឃើញថា ព្យសនកម្មមានលក្ខណៈស្រាល ស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់ ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា៖ នៅថ្ងៃកើតហេតុ កូនក្តីខ្លួនបានទៅផ្ទះរបស់មេភូមិដើម្បីបញ្ជាក់ពីដីធ្លីរបស់កូនក្តីខ្លួន ហើយត្រូវមេភូមិបានប្រាប់ថា ជនរងគ្រោះដែល



Scanned with CamScanner

ត្រូវជាប្អូន បានជំទាស់ ។ កូនក្តីខ្លួនបានមកផ្ទះជនរងគ្រោះ និងបានចាប់ស្មាជនរងគ្រោះ ដើម្បីទៅផ្ទះមេភូមិទាំងអស់គ្នា ជនរងគ្រោះបានរើមិនព្រមទៅ ប៉ុន្តែមិនបានធ្លាក់ពីលើគ្រែទេ ។ សកម្មភាពទាញស្មាជនរងគ្រោះរបស់កូនក្តីខ្លួនមិនមែនជាបទល្មើសទេ ។ សំណូមពរសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួន រួចផុតពីបទចោទ និងរួចផុតពីសំណង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៦ និង ០០នាទី ស្ថិតនៅភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឈ្មោះ [redacted] ផ្លូន បានទៅផ្ទះលោកមេភូមិ ដើម្បីធ្វើលិខិតបញ្ជាក់ដីធ្លីរបស់ខ្លួន ។ ប៉ុន្តែលោកមេភូមិបានប្រាប់ថា ដីនោះត្រូវបានឈ្មោះ [redacted] សុផល ត្រូវជាប្អូនរបស់ឈ្មោះ [redacted] ផ្លូន ជំទាស់។ ពេលនោះជនសង្ស័យឈ្មោះ [redacted] ផ្លូន បានខឹងនិងឈ្មោះ [redacted] សុផល យ៉ាងខ្លាំង ហើយក៏សំដៅទៅផ្ទះរបស់ឈ្មោះ [redacted] សុផល ដែលកំពុងអង្គុយលើគ្រែ រួចក៏មានទំនាស់ពាក្យសម្តីនឹងគ្នា បន្ទាប់មកជនសង្ស័យឈ្មោះ [redacted] ផ្លូន បានចាប់ទាញឈ្មោះ [redacted] សុផល ទម្លាក់ពីលើគ្រែធ្លាក់អុកគូថទៅលើដី ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ផ្លូន បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយក៏មិនបានវាយគេទេ ។ ខ្លួននិងឈ្មោះ [redacted] សុផល ត្រូវជាបងប្អូននឹងគ្នា ។ នៅថ្ងៃកើតហេតុ ខ្លួនមានទំនាស់ជាមួយឈ្មោះ [redacted] សុផល ទាក់ទងនឹងរឿងដីរបស់ខ្លួន ដោយខ្លួនបានទៅហៅ និងទាញដៃឈ្មោះ [redacted] សុផល ដើម្បីទៅផ្ទះមេភូមិទាំងអស់គ្នា ប៉ុន្តែខ្លួនមិនបានទាញឈ្មោះ [redacted] សុផល ទម្លាក់ពីលើគ្រែទេ ។ បច្ចុប្បន្នខ្លួនឈប់ឈ្លោះគ្នាជាមួយឈ្មោះ [redacted] សុផល ទៀតហើយ ។ សំណូមពរ សុំឲ្យតុលាការបញ្ចប់រឿងត្រឹមនេះ ។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល បានឆ្លើយថា ដោយថ្ងៃកើតហេតុ ឈ្មោះ [redacted] ផ្លូន បានដើរមកផ្ទះខ្លួន ពេលនោះខ្លួនកំពុងតែអង្គុយលើគ្រែសណ្តូកជើងមកមុខ ហើយខ្លួនក៏បានសួរទៅ



Scanned with CamScanner

ឈ្មោះ [redacted] ជួន ថា លោកបងទៅណា ស្រាប់តែឈ្មោះ [redacted] ជួន បានចាប់ទាញជើងខ្លួនទាំងពីរទម្លាក់ពីលើគ្រែដែលមានកំពស់មួយម៉ែត្រជាង នៅពេលនោះមានក្បាលរបស់ខ្លួនបានមកទ្រខ្លួន ហើយឈ្មោះ [redacted] ជួន បានយាដៃវៃខ្លួន ក៏ត្រូវក្បាលបានប្រលែងខ្លួន ហើយទៅចាប់ដៃឈ្មោះ [redacted] ជួន ធ្វើឲ្យធ្លាក់អុកគូទមកលើដីបណ្តាលឲ្យឈឺ និងជាំ ។ នៅពេលដែលឈ្មោះ [redacted] ជួន ទាញខ្លួនទម្លាក់ពីលើគ្រែ នៅពេលនោះខ្លួនកំពុងតែមានជំងឺ ក្រោយពីវះកាត់ចំនួនពីរលើកមកហើយ ។ ហើយក្រោយកើតហេតុខ្លួនក៏បានទៅព្យាបាលនៅមន្ទីរពេទ្យឯកជន ។ ហើយឈ្មោះ [redacted] ជួន និងខ្លួនធ្លាប់មានទំនាស់គ្នាពីរឿងដីធ្លី តែពុំដែលបានជួបមុខគ្នាទេ ហើយឈ្មោះ [redacted] ជួន និងខ្លួន ត្រូវជាបងប្អូន ។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] សាម៉ុន បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនបាននៅអង្គុយនិយាយលេងជាមួយឈ្មោះ [redacted] សុផល នៅក្រោមផ្ទះរបស់ឈ្មោះ [redacted] សុផល ដោយគាត់អង្គុយសណ្តូកជើងលើគ្រែ ហើយខ្លួនអង្គុយកៅអី ស្រាប់តែឃើញឈ្មោះ [redacted] ជួន មកសួរនាំរឿងដីធ្លី ហើយបានទាញជើងឈ្មោះ [redacted] សុផល ទម្លាក់ពីលើគ្រែកំពស់ជាងមួយម៉ែត្រ ប៉ុន្តែត្រូវបានខ្លួនចាប់ស្មាគាត់ជាប់ ហើយឈ្មោះ [redacted] ជួន បានយកដៃបំរុងវាយឈ្មោះ [redacted] សុផល ទៀត ខ្លួនក៏បានស្ទុះទៅឃាត់ ដោយលែងឈ្មោះ [redacted] សុផល ទើបបណ្តាលឲ្យអុកគូទទៅដី ។

៥-តាមចម្លើយសាក្សីឈ្មោះ [redacted] សុខឡេង បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនបាននៅអង្គុយលក់ទំនិញនៅផ្ទះ ទល់មុខផ្ទះម្តាយខ្លួនឈ្មោះ [redacted] សុផល ស្រាប់តែឃើញអ៊ុំខ្លួនឈ្មោះ [redacted] ជួន មកសួររកឪពុកខ្លួន តែខ្លួនថា គាត់មិននៅទេ នៅតែម្តាយនៅក្នុងផ្ទះ ។ ឈ្មោះ [redacted] ជួន បានដើរចូលទៅក្នុងផ្ទះម្តាយខ្លួន មួយសន្ទុះក្រោយមក ស្រាប់តែឮសម្លេងវ៉ូសវ៉ាស ខ្លួនក៏ទៅមើលឃើញឈ្មោះ [redacted] សាម៉ុន និងឈ្មោះ [redacted] ចាន់ធា បាននាំគ្នាឃាត់ចាប់ទាញឈ្មោះ [redacted] ជួន ថយចេញ និងឃើញម្តាយខ្លួនដើរទ្រិបទ្រាបៗ មកអង្គុយនៅកាំជណ្តើរផ្ទះ ហើយឈ្មោះ [redacted] សាម៉ុន បានប្រាប់ខ្លួនថា ឈ្មោះ [redacted] ជួន បានទាញជើងម្តាយខ្លួនទម្លាក់ពីលើគ្រែ តែបានគាត់ជួយទាន់ ។

៦-តាមចម្លើយសាក្សីឈ្មោះ [redacted] ចាន់ធា បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួន និងឪពុកខ្លួនឈ្មោះ [redacted] ជួន បាននាំគ្នាទៅផ្ទះមេភូមិ ដើម្បីធ្វើលិខិតបញ្ជាក់ដីធ្លី តែត្រូវមេភូមិប្រាប់ថា ដីនោះឈ្មោះ [redacted] សុផល បានជំទាស់ ឮដូច្នោះឪពុកខ្លួនខឹង និងបានដើរសំដៅផ្ទះឈ្មោះ [redacted] សុផល ហើយបានចាប់ស្មាទាំងសងខាងរបស់ឈ្មោះ [redacted] សុផល និងទាញឲ្យចុះពីលើគ្រែ ដើម្បីទៅផ្ទះមេភូមិ ។ តែឈ្មោះ [redacted] សុផល មិនព្រម ហើយឈ្មោះ [redacted] សាម៉ុន ក៏បានចាប់ទាញស្មាម្ខាងរបស់ឈ្មោះ [redacted] សុផល ទប់កុំឲ្យធ្លាក់ពីលើគ្រែ តែឈ្មោះ



Scanned with CamScanner

[redacted] សុផល ក៏បានរមិលពីលើគ្រែមកឈររលើដី តែគាត់មិនបានធ្លាក់ពីលើគ្រែទេ ចំណែកខ្លួនក៏បានស្ទុះទៅចាប់ឪពុកខ្លួនចេញ ។

៧-តាមរបាយការណ៍លេខ ៤៩៦ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល បានសន្និដ្ឋានថា ឈ្មោះ [redacted] ជួន ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនា ដោយទាញជើងឈ្មោះ [redacted] សុផល បណ្ដាលឱ្យធ្លាក់ពីលើគ្រែកម្ពស់ ១,១០ម៉ែត្រ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៦៖០០ នាទី ប្រាកដមែន ។

៨-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ជនជាប់ចោទបានឆ្លើយថា នៅថ្ងៃកើតហេតុ គឺជនជាប់ចោទពិតជាមានទំនាស់ជាមួយជនរងគ្រោះមែន ហើយបានទាញជើងជនរងគ្រោះ តែមិនធ្លាក់ ។ ឃើញថា ព្យសនកម្មមានលក្ខណៈស្រាល ស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា ។

៩-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា នៅថ្ងៃកើតហេតុ កូនក្ដីខ្លួនបានទៅផ្ទះរបស់មេភូមិដើម្បីបញ្ជាក់ពីដីធ្លីរបស់កូនក្ដីខ្លួន ហើយត្រូវមេភូមិបានប្រាប់ថា ជនរងគ្រោះដែលត្រូវជាប្អូន បានជំទាស់ ។ កូនក្ដីខ្លួនបានមកផ្ទះជនរងគ្រោះ និងបានចាប់ស្មាជនរងគ្រោះ ដើម្បីទៅផ្ទះមេភូមិទាំងអស់គ្នា ជនរងគ្រោះបានរើមិនព្រមទៅ ប៉ុន្តែមិនបានធ្លាក់ពីលើគ្រែទេ ។ សកម្មភាពទាញស្មាជនរងគ្រោះរបស់កូនក្ដីខ្លួនមិនមែនជាបទល្មើសទេ ។ សំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្ដីខ្លួន រួចផុតពីបទចោទ និងរួចផុតពីសំណង ។ តុលាការយល់ឃើញថា ការសន្និដ្ឋាននេះមិនមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ឡើយ គប្បីតុលាការមិនលើកយកការសន្និដ្ឋាននេះមកពិចារណាឡើយ ។

១០-តាមចម្លើយជនជាប់ចោទ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយសាក្សី របាយការណ៍របស់សមត្ថកិច្ច និងតាមឯកសារជាភស្តុតាងនានាក្នុងសំណុំរឿង ឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ នៅចំណុចភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជនជាប់ចោទឈ្មោះ [redacted] ជួន ពិតជាបានទាញជើងឈ្មោះ [redacted] សុផល បណ្ដាលឱ្យធ្លាក់ពីលើគ្រែ ប្រាកដមែន ។

១១-ជនជាប់ចោទឈ្មោះ [redacted] ជួន មានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ នៅចំណុចភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

១២-ជនជាប់ចោទឈ្មោះ [redacted] ជួន ជាសមត្ថជនមានស្មារតីល្អគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នូវរាល់អំពើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ ។



Scanned with CamScanner

១៣-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ជួន បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម និងកំណត់ទុកថាជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោស ។

១៤-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ជួន ភេទប្រុស អាយុ ៦៨ឆ្នាំ ពីបទ ហិង្សាស្រាល ប្រព្រឹត្តនៅចំណុចភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ ។

១៥-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល បានទាមទារសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក គប្បីតុលាការពិចារណា និងសម្រេចតាមភាពសមរម្យជាក់ស្តែង ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] ជួន ភេទប្រុស អាយុ ៦៨ឆ្នាំ ជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ១០០,០០០ **(មួយសែន) រៀល** ពីបទ ហិង្សាស្រាល ប្រព្រឹត្តនៅចំណុចភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] ជួន សងសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលចំនួន **១,០០០,០០០ (មួយលាន) រៀល** ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ **ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២០** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជួន កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល និងប្រកាសជាសាធារណៈ **ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០** ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

កណ្តាល,ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner